**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពង់ស្ពឺ**
**សាលក្រមព្រហ្មទណ្ឌ**
លេខ ២៧៣ (ឌ)
ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៤
សំណុំរឿងព្រហ្មទណ្ឌលេខ: ៩២៧
ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២១
សំណុំរឿងជំនុំជម្រះលេខ: ៥៦៨
ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២

# ក្នុងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកំពង់ស្ពឺ

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តកំពង់ស្ពឺ ថ្ងៃទីម្ភៃប្រាំមួយ ខែមករា ឆ្នាំពីរពាន់ម្ភៃបួន វេលាម៉ោង ដប់ ព្រឹក ដោយមានសមាសភាពដូចតទៅ

## ក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ សាលាដំបូងខេត្តកំពង់ស្ពឺ
-លោក [redacted] ជាសមាជិកក្រុមប្រឹក្សាជំនុំជម្រះ សាលាដំបូងខេត្តកំពង់ស្ពឺ
-លោក [redacted] ជាសមាជិកក្រុមប្រឹក្សាជំនុំជម្រះ សាលាដំបូងខេត្តកំពង់ស្ពឺ

## តំណាងអយ្យការ

-លោក [redacted] ជាព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តកំពង់ស្ពឺ

## ក្រឡាបញ្ជីសវនាការ

-លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូង សាលាដំបូងខេត្តកំពង់ស្ពឺ

## មេធាវី

-លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ភ័ក្ត្រា
-លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] គីមជាតិ
-លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] រី

## <u>ដើម្បីជំនុំជម្រះលើ</u>

១./ ជនជាប់ចោទឈ្មោះ [redacted] ភក្ត្រា ហៅ ញ៉ាញ់ ភេទប្រុស កើតឆ្នាំ១៩៨៨ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ មិនពិតប្រាដក ទីកន្លែងកំណើតនៅភូ[redacted] ខេត្តកណ្ដាល ទីលំនៅបច្ចុប្បន្ននៅភូមិថ្មីទំលាប់ ឃុំចាន់សែន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] រ័ត្ន (រ) ម្ដាយឈ្មោះ [redacted] ណារី (រ) ប្រពន្ធឈ្មោះ [redacted] អាន មានកូន០២នាក់, ទោសពីមុនគ្មាន។

**ត្រូវបានឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៦១៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១។**



Scanned with CamScanner

ជាប់ចោទពីបទ **រក្សាទុក និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិថ្មីទំលាប់ ឃុំចាន់សែន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៦ ចំណុច៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២./ ជនជាប់ចោទឈ្មោះ [redacted] **រី** ហៅរ៉ាវី ភេទប្រុស កើតឆ្នាំ១៩៩៨ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកសិករ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពង់ស្ពឺ បច្ចុប្បន្ននៅភូមិ [redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] ថា (រ) ម្តាយឈ្មោះ [redacted] យ៉ាន (រ), នៅលីវ, ទោសពីមុនគ្មាន។

**ត្រូវបានឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៣៧១ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣។**

៣./ ជនជាប់ចោទឈ្មោះ [redacted] **គីមជាតិ** ហៅ ជាតិ ភេទប្រុស កើតឆ្នាំ១៩៨៦ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ កសិករ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពង់ស្ពឺ បច្ចុប្បន្ននៅភូមិ [redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] យឿន (ស) ម្តាយឈ្មោះ [redacted] សុខ (ស), ប្រពន្ធឈ្មោះ [redacted] ស៊ីណា មានកូន០៣នាក់, ទោសពីមុនគ្មាន។

៤./ ជនជាប់ចោទឈ្មោះ [redacted] **ហួរ** ហៅហួរ ភេទប្រុស កើតឆ្នាំ១៩៨៧ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ កសិករ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពង់ស្ពឺ បច្ចុប្បន្ននៅភូមិ [redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] ហ៊ុយ (រ) ម្តាយឈ្មោះ [redacted] ញ៉ៀន (រ), ប្រពន្ធឈ្មោះ [redacted] ចន្ធី មានកូន០៤នាក់, ទោសពីមុនគ្មាន។

ជាប់ចោទពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិថ្មីទំលាប់ ឃុំចាន់សែន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ កាលពីដើមខែមករា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៦ ចំណុច៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## ការប្រព្រឹត្តរបស់ជនជាប់ចោទ

កាលពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង១៥ ស្ថិតនៅភូមិថ្មីទំលាប់ ឃុំចាន់សែន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ កម្លាំងនៃអធិការដ្ឋាននគរបាលស្រុកឧដុង្គ បានធ្វើការបង្ក្រាបករណី រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដោយបានឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] ភ័ក្រ្តា ហៅ ញ៉ាញ់ ដកហូតបានគ្រឿងញៀនចំនួន ៤ កញ្ចប់ ទម្ងន់ ១០៤,១៤ (មួយរយបួន ក្បៀសដប់បួន) ក្រាម, ជញ្ជីងអេឡិចត្រូនិចសម្រាប់ថ្លឹងគ្រឿងញៀនចំនួន ២គ្រឿង, កាំភ្លើងខ្យល់ចំនួន១ដើម និងដាវចំនួន៣ដើម។

-បានឃើញរបាយការណ៍សំយោគលេខ ១០៨ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២១ របស់ស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ ការិយាល័យប្រឆាំងគ្រឿងញៀន។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៨៤៦២ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៣៧៤២ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ។



Scanned with CamScanner

-បានឃើញដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤៦៤ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តកំពង់ស្ពឺ។

-បានឃើញដីកាចាត់តាំងសមាសភាពក្រុមប្រឹក្សាជំនុំជម្រះលេខ ៩៣២ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ ២០២៣ របស់សាលាដំបូងខេត្តកំពង់ស្ពឺ។

-បានឃើញដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ១៦៦ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ សាលាដំបូងខេត្តកំពង់ស្ពឺ។

-បានឃើញសាលក្រមមុនអង្គសេចក្តីលេខ ១៥ (ជ) ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តកំពង់ស្ពឺ។

-បានឃើញការផ្តល់ និងជូនដំណឹងអំពីកាលបរិច្ឆេទ នៃសវនាការដែលធ្វើឡើងដោយអនុលោមតាមបញ្ញត្តិមាត្រា ២៩២ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## **នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] ភក្ត្រា ហៅ ញ៉ាញ់ បានឆ្លើយថា កាលពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ម៉ោង ០៧ព្រឹក ខ្លួនបានជិះម៉ូតូទៅទិញគ្រឿងញៀនពីឈ្មោះ ជាតិ ភេទប្រុស អាយុប្រហែល៤០ឆ្នាំ រស់នៅភូមិត្រពាំងតាមាន់ ឃុំព្នាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ក្នុងតម្លៃ ៣.៧០០.០០០ (បីលានចិតសិបម៉ឺន) រៀល បានពីរកញ្ចប់ រួចជិះម៉ូតូត្រឡប់មកផ្ទះវិញ ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ ខ្លួនចាប់ផ្តើមលក់គ្រឿងញៀនពីឆ្នាំ២០១៩ ដោយទិញម្តងៗពី ១០០.០០០ (ដប់ម៉ឺន) រៀល ទៅ ២០០.០០០ (ម្ភៃម៉ឺន) រៀល យកមកវ៉ែចែកជាកញ្ចប់តូចៗលក់វិញក្នុងមួយកញ្ចប់ពី ២០.០០០ (ពីរម៉ឺន) រៀល ទៅ ៣០.០០០ (បីម៉ឺន) រៀល។ ចំពោះគ្រឿងញៀន ខ្លួនធ្លាប់បានទិញពីឈ្មោះ ហួរ ឈ្មោះ ជាតិ និងប្រើឈ្មោះ រ៉ាវី។ ក្រោយមកមានអ្នកលេងមាន់ជល់មិនស្គាល់ឈ្មោះបានទិញគ្រឿងញៀនពីខ្លួនចំនួនពីរលើក លើកទី១ តម្លៃ ១.៧០០.០០០ (មួយលានចិតសិបម៉ឺន) រៀល លើកទី២ តម្លៃ ៤.៥០០.០០០ (បួនលានហាសិបម៉ឺន) រៀល ប៉ុន្តែខ្លួនទៅទិញពីឈ្មោះ ជាតិ ត្រឹមតែ ៣.៧០០.០០០ (បីលាន ចិតសិបម៉ឺន) រៀល ដើម្បីលក់ឱ្យគាត់។ នៅពេលឃាត់ខ្លួនសមត្ថកិច្ចបានដកហូតគ្រឿងញៀនចំនួន២កញ្ចប់ ទម្ងន់ជាង ១០០ ក្រាម។ ចំពោះឈ្មោះ ជាតិ ខ្លួនមិនស្គាល់ច្បាស់នោះទេ។ ឈ្មោះ ជាតិ អាយុប្រហែល ២០ ទៅ ៣០ ឆ្នាំ កម្ពស់ខ្ពស់ និងសម្បុរស ចំពោះម្នាក់ដែលឈរជិតខ្លួននៅពេលនេះមិនមែនឈ្មោះ ជាតិ ([redacted] គឹមជាតិ) ដែលខ្លួនបានទិញគ្រឿងញៀនពីគាត់នោះទេ។ ចំណែកឈ្មោះ [redacted] ហួរ ខ្លួនមិនធ្លាប់ស្គាល់នោះទេ។ ខ្លួនក៏មិនធ្លាប់ទិញគ្រឿងញៀនពីឈ្មោះ [redacted] ហួរ ផងដែរ។ ឈ្មោះ [redacted] វី ខ្លួនមិនស្គាល់មុខនោះទេ ប៉ុន្តែខ្លួនស្គាល់ភិនភាគ កម្ពស់រាងទាប។ ខ្លួនមិនស្គាល់ ឈ្មោះ [redacted]វី ទេ ប៉ុន្តែឈ្មោះ រ៉ាវី ខ្លួនធ្លាប់ ស្គាល់។ ចំពោះម្នាក់ដែលឈរនៅជិតខ្លួននេះមិនមែនឈ្មោះ រ៉ាវី ដែលខ្លួនធ្លាប់ទិញគ្រឿងញៀននោះទេ។ ខ្លួនសំណូមពរសូមឱ្យតុលាការជួយបន្ធូរបន្ថយទោសផង។ ខ្លួនធ្លាប់ទិញពីឈ្មោះ ហួរ នៅឆ្នាំ២០១៩ មិនធ្លាប់ទិញពីឈ្មោះ[redacted]វី ទេ។ ខ្លួនទិញពីឈ្មោះ ជាតិ ៣លើក ទី១ ១០ម៉ឺន ទី២ ១០ ម៉ឺន ទី៣ ៥លានរៀល។ ដឹងខ្លួនខុសហើយសន្យាក្រោយពេលចេញទៅវិញ ឈប់ប្រព្រឹត្តបែបនឹងទៀតហើយ ខ្លួនមានកូនតូចនៅផ្ទះ។



Scanned with CamScanner

-ជនជាប់ចោទឈ្មោះ [redacted] **គីមជាតិ** ហៅ ជាតិ បានឆ្លើយថា កាលដើមខែមករា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ខ្លួនមិនបានប្រព្រឹត្តអំពើជួញដូរគ្រឿងញៀនដោយខុសច្បាប់ដូចការចោទប្រកាន់របស់តំណាងអយ្យការទេ។ ចំពោះឈ្មោះ [redacted] ភក្ត្រា ហៅ ញ៉ាញ់ ឈ្មោះ ហួរ ឈ្មោះ រ៉ាវី ខ្លួនមិនដែលស្គាល់ទេ។ ខ្លួនមិនចេះប្រើប្រាស់គ្រឿងញៀន និងមិនធ្លាប់លក់គ្រឿងញៀនទេ។ ខ្លួនបានចាកចេញពីភូមិត្រពាំងតាមាន់ ឃុំញ្ញាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ទៅរស់នៅខាងប្រពន្ធនៅភូមិថ្មីជង្រុក ឃុំយារអង្គ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ តាំងពីឆ្នាំ២០១០ ហើយប្រកបមុខរបរជាអ្នកលក់សាច់ជ្រូក ត្រី បន្លែ និងបង្អែម (ជិកតាមម៉ូតូ) នៅភូមិពាណិជ្ជ ភូមិរំចេក ភូមិព្រៃធំ ក្នុងឃុំយារអង្គ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ មិនដែលទៅលក់ដល់ភូមិត្រពាំងតាមាន់ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺទេ។ ខ្លួនប្រកបមុខរបរនេះតាំងតែពីខ្លួនការប្រពន្ធក្នុងឆ្នាំ២០១០ រហូតដល់សព្វថ្ងៃ។ ចាប់តាំងពីខ្លួនចាកចេញពីស្រុកកំណើតភូមិត្រពាំងតាមាន់ ឃុំញ្ញាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ទៅរស់នៅខាងប្រពន្ធមក ខ្លួនមិនដែលទៅលេងស្រុកកំណើតទេ ព្រោះឪពុកម្តាយ របស់ខ្លួនបានស្លាប់តាំងពីមុនខ្លួនមិនទាន់ការប្រពន្ធ គឺទៅលេងប្អូនបានត្រឹមតែមួយដងទៅពីដងតែប៉ុណ្ណោះក្នុងមួយឆ្នាំ។ ខ្លួនសូមឱ្យតុលាការជួយរកយុត្តិធម៌ដល់ខ្លួនផង។ សូមរក្សាចម្លើយដែលខ្លួនបានឆ្លើយពីមុននៅ ដដែល។ ខ្លួនមិនស្គាល់ឈ្មោះ [redacted] ភក្ត្រា នោះទេ ចំពោះពីរនាក់ដែលកំពុងឈរនៅខាងក្រោយខ្លួននៅពេលនេះ ([redacted] ភក្ត្រា និងឈ្មោះ [redacted] វី) ខ្លួនមិនស្គាល់នោះទេ។ "ជនជាប់ចោទឈ្មោះ [redacted] ភក្ត្រា បានឆ្លើយថា ចម្លើយកាលពីមុនខ្លួនបានឆ្លើយថា បានទិញគ្រឿងញៀនពីឈ្មោះ ជាតិ ប៉ុន្តែមិនមែនឈ្មោះ ជាតិ ដែលកំពុងតែឈរនៅកន្លែងនេះនោះទេ" ។

-ជនជាប់ចោទឈ្មោះ [redacted] វី បានឆ្លើយថា ខ្លួនប្រើប្រាស់គ្រឿងញៀនបាន ៧ ទៅ ៨ ខែហើយ។ ខ្លួនមិនធ្លាប់ជួញដូរគ្រឿងញៀននោះទេ។ ខ្លួនមិនធ្លាប់ស្គាល់ឈ្មោះ [redacted] ភក្ត្រា, ឈ្មោះ ហួរ និងឈ្មោះ រ៉ាវី នោះទេ។ ខ្លួនឈ្មោះ [redacted] វី មិនមែនឈ្មោះ [redacted] វី នោះទេ។ សមត្ថកិច្ចចាប់ខ្លួនដោយបានអះអាងថាខ្លួនឈ្មោះ [redacted] វី ខ្លួនបានប្រកែកដែរ ប៉ុន្តែសមត្ថកិច្ចនៅតែអះអាងថាខ្លួនពិតជាឈ្មោះ [redacted] វី មែនហើយ។ កន្លងមកខ្លួនធ្លាប់ទិញគ្រឿងញៀនពីឈ្មោះ ហេល ហើយត្រូវ ប៉ូលិសចាប់ខ្លួន ប៉ុន្តែមិនពាក់ព័ន្ធក្នុងរឿងនេះទេ។ ខ្លួនសំណូមពរសូមឱ្យតុលាការជួយរកយុត្តិធម៌ឱ្យខ្លួនផង។ចម្លើយដែលបានឆ្លើយនៅពេលមុនគឺរក្សានៅដដែល។ ខ្លួនមិនស្គាល់ឈ្មោះ [redacted] ភក្ត្រា ដែលកំពុងមានវត្តមាននៅទីនេះទេ។ សមត្ថកិច្ចចាប់ខ្លួនរូបខ្លួន គឺចាប់នៅក្នុងរឿងគ្រឿងញៀនផ្សេងទៀត ហើយក៏បានបញ្ចូលរូបខ្លួនមកក្នុងរឿងនេះបន្ថែមទៀត។ រឿងហេតុដែលបានចោទប្រកាន់ខ្លួននៅពេលនេះខ្លួនមិនបានប្រព្រឹត្តនោះទេ។

-ចម្លើយសាក្សីឈ្មោះ [redacted] **ប៊ុនឆេង** បានឆ្លើយថា ខ្លួនមាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ (សម្បថនៅសាលាឧទ្ធរណ៍ភ្នំពេញ) បច្ចុប្បន្នខ្លួនជានាយប៉ុស្តិ៍នគរបាលរដ្ឋបាលស្តីទីពាំងល្វា។ ខ្លួនឡើងជានាយប៉ុស្តិ៍នគរបាលរដ្ឋបាលចាន់សែន ក្នុងឆ្នាំ២០១១ បច្ចុប្បន្នខ្លួនជានាយប៉ុស្តិ៍នគរបាលរដ្ឋបាលស្តីទីពាំងល្វា ស្រុកសាមគ្គីមុនីជ័យ ខេត្តកំពង់ស្ពឺ។ ខ្លួនបានទទួលដីកាចាត់ឱ្យស៊ើបសួរជំនួសលេខ ១១៩៩៧ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ស្ពឺ លើឈ្មោះ រ៉ាវី ភេទប្រុស អាយុប្រហែល២២ឆ្នាំ អាសយដ្ឋានភូមិត្រពាំងអំពិល ឃុំចាន់សែន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ។ ខ្លួនក៏បានចុះទៅស្រាវជ្រាវយកសាវតារជាតិឈ្មោះខាងលើដោយផ្ទាល់ ដោយខ្លួនបានទៅស្រង់យកសាវតារជាតិឈ្មោះនេះ



Scanned with CamScanner

ក្នុងសៀវភៅ ក១ (សៀវភៅគ្រប់គ្រងប្រជាពលរដ្ឋក្នុងភូមិត្រពាំងអំពិល) ឃើញថា ឈ្មោះ [redacted] វី ភេទប្រុស កើតថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៩៨ កម្រិតវប្បធម៌ថ្នាក់ទី៨ថ្មី ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិត្រពាំងអំពិល ឃុំចាន់សែន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ទីលំនៅសព្វថ្ងៃនៅភូមិត្រពាំងអំពិល ឃុំចាន់សែន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] ថា (រស់) ម្ដាយឈ្មោះ [redacted] យ៉ាន (រស់) នៅលីវ, ទោសពីមុន គ្មាន។ ខ្លួនក៏បានធ្វើសន្លឹកសារពារជាតិឈ្មោះខាងលើ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ ដើម្បីធ្វើរបាយការណ៍ជូនតុលាការតាមនីតិវិធីច្បាប់។ ចំពោះឈ្មោះ [redacted] វី នេះ ក្នុងសៀវភៅ ក១ ពុំមានចុះឈ្មោះហៅក្រៅនោះទេ ប៉ុន្តែឈ្មោះនេះ ប្រជាពលរដ្ឋក្នុងភូមិបានហៅវា [redacted] រ៉ា វី។ ឈ្មោះ [redacted] វី ជាមុខសញ្ញាពាក់ព័ន្ធនឹងគ្រឿងញៀនយូរឆ្នាំមកហើយ។ ឈ្មោះនេះបានចាប់ផ្ដើមជួញដូរគ្រឿងញៀនតាំងពីថ្ងៃខែឆ្នាំណា ខ្លួនពុំបានដឹងទេ ប៉ុន្តែខាងសមត្ថកិច្ចយើងអាចកំណត់បានថាឈ្មោះ [redacted] វី ជាមុខសញ្ញាជួញដូរគ្រឿងញៀន តាំងពីក្នុងអំឡុងខែមករា ឆ្នាំ២០២៣ ដោយប្រជាការពារភូមិ ឈ្មោះ [redacted] ប៊ុនធុន បានរាយការណ៍មកខ្លួនថា “ប្រជាពលរដ្ឋក្នុងភូមិបានរាយការណ៍មកថា ឈ្មោះ [redacted] វី ពាក់ព័ន្ធនឹងករណីចែកចាយគ្រឿងញៀន” បន្ទាប់ពីខ្លួនបានទទួលដំណឹង ខ្លួនក៏បានរាយការណ៍ជូនលោកអធិការរងផែនប្រឆាំងបទល្មើសគ្រឿងញៀន នៃអធិការដ្ឋាននគរបាលស្រុកឧដុង្គ ព្រោះខាងសមត្ថកិច្ចប៉ុស្តិ៍ពុំមានសមត្ថកិច្ចចុះបង្ក្រាបឡើយ។ ឈ្មោះ [redacted] ប៊ុនធុន សព្វថ្ងៃនៅជាប្រជាការពារភូមិត្រពាំងអំពិលដដែល សព្វថ្ងៃគាត់រស់នៅភូមិត្រពាំងអំពិល ឃុំចាន់សែន ស្រុកសាមគ្គីមុនីជ័យ ខេត្តកំពង់ស្ពឺ។ នៅក្នុងរឿងនេះ ខ្លួនបានដឹងរឿងតែប៉ុណ្ណឹងទេ។

-ចម្លើយសាក្សីឈ្មោះ [redacted] **វឿន** បានឆ្លើយថា ខ្លួនសូមឆ្លើយក្នុងនាមជាសាក្សី ខ្លួនបានស្បថនៅមុខអ្នកតាក្រហមករួចហើយ ខ្លួនសូមឆ្លើយតែការពិតដែលខ្លួនបានឃើញ បានឮ បានដឹង និងបានចាំផ្ទាល់។ ខ្លួនឡើងជាមេភូមិត្រពាំងតាមាន់ តាំងពីឆ្នាំ២០១៤ រហូតមកដល់បច្ចុប្បន្ន។ នៅក្នុងរឿងនេះ ខ្លួនពុំធ្លាប់បានទទួលដីកាចាត់ឱ្យស៊ើបសួរជំនួសពីតុលាការឡើយ។ ចំពោះឈ្មោះ ជាតិ ក្នុងសៀវភៅ ក១ (សៀវភៅគ្រប់គ្រងប្រជាពលរដ្ឋក្នុងភូមិត្រពាំងតាមាន់) មានតែម្នាក់ប៉ុណ្ណោះ ដោយគាត់មានឈ្មោះ [redacted] គីមជាតិ ភេទប្រុស កើតឆ្នាំ១៩៨៦ មុខរបរធ្វើស្រែ សញ្ជាតិខ្មែរ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិត្រពាំងតាមាន់ ឃុំផ្លាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ទីលំនៅសព្វថ្ងៃនៅភូមិត្រពាំងតាមាន់ ឃុំញ្ញាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] ឈឿន (ស្លាប់) ម្ដាយឈ្មោះ [redacted] សុខ (ស្លាប់) ប្រពន្ធឈ្មោះ [redacted] ស៊ីណា (រស់) មានកូន ៣នាក់ ប៉ុន្តែឈ្មោះ [redacted] គីមជាតិ នេះ បានទៅរស់នៅភូមិថ្មី ឃុំយាអង្គ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ តាំងពីគាត់រៀបការជាមួយប្រពន្ធគាត់មកម្ល៉េះ ប៉ុន្តែគាត់ពុំបានធ្វើឯកសារផ្លាស់ទីលំនៅឡើយ។ ចំពោះឈ្មោះ [redacted] គីមជាតិ នេះ ក្នុងសៀវភៅ ក១ ពុំមានចុះឈ្មោះហៅក្រៅនោះទេ ប៉ុន្តែឈ្មោះនេះខ្លួនហៅគាត់ថា ជាតិ។ ឈ្មោះ [redacted] គីមជាតិ ហៅ ជាតិ ជាមុខសញ្ញាពាក់ព័ន្ធនឹងគ្រឿងញៀន ឬអត់នោះខ្លួនពុំបានដឹងទេ ព្រោះគាត់បានទៅរស់នៅភូមិថ្មី ឃុំយាអង្គ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ តាំងពីឆ្នាំ២០១០ មកម្ល៉េះ ដោយគាត់មានមុខរបរ កសិករ និងដុតឡឥដ្ឋ។ បច្ចុប្បន្នឈ្មោះនេះមានមុខរបរធ្វើបន្ថែមទៀតនោះខ្លួនពុំបានដឹងទេ។ ខ្លួនពុំបានដឹងថាឈ្មោះ [redacted] គីមជាតិ មានជាប់ពាក់ព័ន្ធនឹងគ្រឿងញៀនឬអត់នោះទេ ហើយនៅក្នុងមូលដ្ឋានខ្លួនមានឈ្មោះ ជាតិ តែឈ្មោះ [redacted] គីមជាតិ តែម្នាក់ប៉ុណ្ណោះ។ ខ្លួនសូមបញ្ជាក់បន្ថែមថា អំឡុងពេលឈ្មោះ [redacted] គីមជាតិ រស់នៅក្នុងភូមិ



Scanned with CamScanner

ត្រពាំងតាមាន់ ឃុំធ្លាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ គាត់ពុំធ្លាប់មានប្រព្រឹត្តបទល្មើសអ្វីឡើយ ហើយឈ្មោះនេះក៏ធ្លាប់បួសរៀននៅវត្តផែមខ្លួន ហៅវត្តត្រពាំងតាមាន់ បាន ៥វស្សា ក្រោយពីគាត់លាចាកសិក្ខាបទរួច គាត់ក៏បានរៀបការប្រពន្ធ ហើយគាត់ក៏បានទៅរស់នៅខាងប្រពន្ធគាត់នៅភូមិថ្មី ឃុំយាអង្គ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ចាប់តាំងពីនោះមកគាត់បានប្រព្រឹត្តបទល្មើសអ្វី ឬមិនបានប្រព្រឹត្តខ្លួនពុំបានដឹងទេ។ នៅក្នុងរឿងនេះ ខ្លួនបានដឹងរឿងតែប៉ុណ្ណឹងទេ។

-ចម្លើយសាក្សីឈ្មោះ [redacted] ខេន បានឆ្លើយថា ខ្លួនសូមឆ្លើយក្នុងនាមជាសាក្សី ខ្លួនបានស្បថនៅមុខអ្នកតាក្រហមករួចហើយ ខ្លួនសូមឆ្លើយតែការពិតដែលខ្លួនបានឃើញ បានឮ បានដឹង និងបានចាំផ្ទាល់។ ខ្លួនឡើងជាមេភូមិថ្មីជង្រុក តាំងពីឆ្នាំ១៩៩៨ រហូតមកដល់បច្ចុប្បន្ន។ នៅក្នុងរឿងនេះ ខ្លួនពុំធ្លាប់បានទទួលដីកាចាត់ឱ្យស៊ើបសួរជំនួសពីតុលាការឡើយ។ ចំពោះឈ្មោះ [redacted] គីមជាតិ ក្នុងសៀវភៅ ក១ (សៀវភៅគ្រប់គ្រងប្រជាពលរដ្ឋក្នុងភូមិថ្មីជង្រុក) ពុំមានឈ្មោះគាត់ទេ ដោយគាត់ពុំបានផ្លាស់ទីលំនៅពីភូមិត្រពាំងតាមាន់ មករស់នៅភូមិថ្មីជង្រុកឡើយ។ ប៉ុន្តែគាត់បានមករស់នៅក្នុងភូមិថ្មីជង្រុក ឃុំយាអង្គ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ តាំងពីឆ្នាំ២០១០ មកម្ល៉េះ បន្ទាប់ពីគាត់រៀបការជាមួយប្រពន្ធគាត់ ព្រោះប្រពន្ធគាត់ជាប្រជាពលរដ្ឋរស់នៅក្នុងភូមិថ្មីជង្រុក ឃុំយាអង្គ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ។ ឈ្មោះ [redacted] គីមជាតិ ភេទប្រុស កើតឆ្នាំ១៩៨៦ មុខរបរលក់ បន្លែត្រីសាច់ សញ្ជាតិខ្មែរ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិត្រពាំងតាមាន់ ឃុំធ្លាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងតាមាន់ ឃុំធ្លាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ (បច្ចុប្បន្នមករស់នៅជាមួយ ប្រពន្ធនៅភូមិថ្មីជង្រុក ឃុំយាអង្គ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ) ប្រពន្ធឈ្មោះ [redacted] ស៊ីណា (រស់) មានកូន៣នាក់។ ពេលដែលឈ្មោះ [redacted] គីមជាតិ មករស់នៅក្នុងភូមិថ្មីជង្រុក គាត់មានមុខរបរកសិករ និងដុតឡធ្យូង ក្រោយមកគាត់ និងប្រពន្ធគាត់ក៏បានដឹកបន្លែត្រីសាច់លក់តាមម៉ូតូលក់ក្នុងភូមិ។ ឈ្មោះ [redacted] គីមជាតិ នេះ ប្រជាពលរដ្ឋរស់នៅក្នុងភូមិព្រមទាំងខ្លួនហៅគាត់ថា ជាតិ។ ខ្លួនសូមបញ្ជាក់ថា ឈ្មោះ [redacted] គីមជាតិ ហៅ ជាតិ ពុំមែនជាមុខសញ្ញាពាក់ព័ន្ធនឹងគ្រឿងញៀននោះទេ។ តាំងពីឈ្មោះ [redacted] គីមជាតិ ហៅ ជាតិ មករស់នៅក្នុងមូលដ្ឋានភូមិថ្មីជង្រុកមក គាត់ពុំធ្លាប់ប្រព្រឹត្តបទល្មើសអ្វីឡើយ គាត់ជាប្រជាពលរដ្ឋល្អក្នុងភូមិ ពុំដែលផឹកស៊ីរញ៉េរញ៉ៃឡើយ ដឹងតែរកស៊ីចិញ្ចឹមគ្រួសារ។ គាត់ និងអ្នកជិតខាងភូមិផងរបងជាមួយក៏ពុំធ្លាប់មានទំនាស់អ្វីដែរ។ ចំពោះស្ថានភាពក្នុងគ្រួសារគាត់ក៏ពុំធ្លាប់មានជម្លោះដែរ។ ខ្លួនសូមបញ្ជាក់បន្ថែមថា មូលដ្ឋានភូមិសាស្ត្រខ្លួន គឺភូមិថ្មីជង្រុក ពុំមែនភូមិថ្មី ឡើយ។ កន្លងមកឈ្មោះ [redacted] គីមជាតិ ហៅ ជាតិ ធ្លាប់បួសឬអត់នោះខ្លួនពុំបានដឹងទេ។ នៅក្នុងរឿងនេះខ្លួនបានដឹងរឿងតែប៉ុណ្ណឹងទេ។ ឈ្មោះ [redacted] គីមជាតិ ជាអ្នករស់នៅក្នុងភូមិខ្លួន ដោយបានចូលមករស់នៅឆ្នាំ២០១០ ឈ្មោះ ជាតិ មានតែម្នាក់នេះទេ។ ឈ្មោះនេះមិនដែលធ្វើអ្វីឱ្យប៉ះពាល់សង្គមទេ។

-ចម្លើយសាក្សីឈ្មោះ [redacted] ឈាន បានឆ្លើយថា ខ្លួនមាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ (សម្បថនៅសាលាឧទ្ធរណ៍ភ្នំពេញ) បច្ចុប្បន្នខ្លួនជានាយប៉ុស្តិ៍នគរបាលរដ្ឋបាលធ្លាយ។ ខ្លួនឡើងជានាយប៉ុស្តិ៍នគរបាលរដ្ឋបាលធ្លាយ តាំងពីឆ្នាំ២០១២ រហូតមកដល់បច្ចុប្បន្ន។ ខ្លួនបានទទួលដីកាចាត់ឱ្យស៊ើបសួរជំនួសលេខ ១១៩៩៦ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកំពង់ស្ពឺ លើឈ្មោះ ជាតិ



Scanned with CamScanner

ភេទប្រុស អាយុ៤០ឆ្នាំ អាសយដ្ឋានភូមិត្រពាំងតាមាន់ ឃុំញាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។ ខ្លួនក៏បានចាត់លោក [redacted] ប៊ុនធឿន ជាមន្ត្រីប៉ុស្តិ៍នគរបាលរដ្ឋបាលញាយដើម្បីចុះទៅស៊ើបសួរ និងស្រាវជ្រាវរកសាវតាជាតិលើឈ្មោះខាងលើ។ លោក [redacted] ប៊ុនធឿន បានជួបជាមួយលោក [redacted] សារិទ្ធ ជាមេភូមិរង ភូមិត្រពាំងតាមាន់ ដើម្បីសាកសួរយកសាវតាជាតិឈ្មោះខាងលើក្នុងសៀវភៅ ក១ (សៀវភៅគ្រប់គ្រងប្រជាពលរដ្ឋក្នុងភូមិត្រពាំងតាមាន់) ឃើញថា ឈ្មោះ [redacted] គីមជាតិ ភេទប្រុស កើតឆ្នាំ១៩៨៦ មុខរបរធ្វើស្រែ សញ្ជាតិខ្មែរ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិត្រពាំងតាមាន់ ឃុំញាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ទីលំនៅសព្វថ្ងៃនៅភូមិត្រពាំងតាមាន់ ឃុំញាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] ឈឿន (ស្លាប់) ម្តាយឈ្មោះ [redacted] សុខ (ស្លាប់) ប្រពន្ធឈ្មោះ [redacted] ស៊ីណា (រស់) មានកូន៣នាក់។ ប៉ុន្តែតាមការបញ្ជាក់បន្ថែមរបស់លោក [redacted] សារិទ្ធ បានបញ្ជាក់ថា ឈ្មោះ [redacted] គីមជាតិ នេះ បានទៅរស់នៅភូមិថ្មី ឃុំយាអង្គ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ តាំងពីគាត់រៀបការជាមួយប្រពន្ធគាត់ មកម្លេះ ប៉ុន្តែគាត់ពុំបានធ្វើឯកសារផ្លាស់ទីលំនៅឡើយ។ ខ្លួនក៏បានធ្វើសន្លឹកសាវតារជាតិលើឈ្មោះខាងលើ ចុះថ្ងៃទី០៨ ខែ វិច្ឆិកា ឆ្នាំ២០២១ ដើម្បីធ្វើរបាយការណ៍ជូនតុលាការតាមចាត់ការតាមនីតិវិធីច្បាប់។ ចំពោះឈ្មោះ [redacted] គីមជាតិ នេះក្នុងសៀវភៅ ក១ ពុំមានចុះឈ្មោះហៅក្រៅនោះទេ ប៉ុន្តែឈ្មោះនេះមេភូមិ និងមេភូមិរងហៅគាត់ថា ជាតិ។ ឈ្មោះ [redacted] គីមជាតិ ហៅ ជាតិ ជាមុខសញ្ញាពាក់ព័ន្ធនឹងគ្រឿងញៀនឬអត់នោះខ្លួនពុំបានដឹងទេ ព្រោះគាត់បានទៅរស់នៅភូមិថ្មី ឃុំយាអង្គ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ តាំងពីឆ្នាំ២០១០ មកម្លេះ ដោយគាត់មានមុខរបរ កសិករ និងជុតឡុង។ បច្ចុប្បន្នឈ្មោះនេះមានមុខរបរធ្វើបន្ថែមទៀតនោះខ្លួនពុំបានដឹងទេ។ តាមសន្លឹកសាវតាជាតិ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២១ ខ្លួនពុំដឹងថាឈ្មោះ [redacted] គីមជាតិ មានជាប់ពាក់ព័ន្ធនឹងគ្រឿងញៀនឬអត់នោះទេ ហើយនៅក្នុងមូលដ្ឋានខ្លួនមានឈ្មោះ ជាតិ តែឈ្មោះ [redacted] គីមជាតិ តែម្នាក់ប៉ុណ្ណោះ។ ខ្លួនសូមបញ្ជាក់បន្ថែមថា អំឡុងពេលឈ្មោះ [redacted] គីមជាតិ រស់នៅក្នុងភូមិត្រពាំងតាមាន់ ឃុំញាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ គាត់ពុំធ្លាប់មានប្រព្រឹត្តបទល្មើសអ្វីឡើយ ហើយឈ្មោះនេះក៏ធ្លាប់បួសរៀននៅវត្តឆែមខ្លួន ហៅវត្តត្រពាំងតាមាន់បាន៥វស្សា ក្រោយពីគាត់លាចាកសិក្ខាបទរួច គាត់ក៏បានរៀបការប្រពន្ធ ហើយគាត់ក៏បានទៅរស់នៅខាងប្រពន្ធគាត់នៅភូមិថ្មី ឃុំយាអង្គ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ចាប់តាំងពីនោះមកគាត់បានប្រព្រឹត្តបទល្មើសអ្វី ឬមិនបានប្រព្រឹត្តខ្លួនពុំបានដឹងទេ។ នៅក្នុងរឿងនេះខ្លួនបានដឹងរឿងតែប៉ុណ្ណឹងទេ។

-ចម្លើយសាក្សីឈ្មោះ [redacted] វ៉ាន់ បានឆ្លើយថា ខ្លួនសូមឆ្លើយក្នុងនាមជាសាក្សី ខ្លួនបានស្បថនៅមុខអ្នកតាក្រហមករួចហើយ ខ្លួនសូមឆ្លើយតែការពិតដែលខ្លួន បានឃើញ បានឮ បានដឹង និងបានចាំផ្ទាល់។ ខ្លួនឡើងជាមេភូមិត្រពាំងអំពិល តាំងពីឆ្នាំ១៩៩៣ រហូតមកដល់បច្ចុប្បន្ន។ នៅក្នុងរឿងនេះ ខ្លួនពុំធ្លាប់បានទទួលដីកាចាត់ឱ្យស៊ើបសួរជំនួសពីតុលាការឡើយ។ ចំពោះឈ្មោះ វ៉ាវី ក្នុងសៀវភៅ ក១ (សៀវភៅគ្រប់គ្រងប្រជាពលរដ្ឋក្នុងភូមិត្រពាំងតាមាន់) ពុំមាននោះទេ មានតែឈ្មោះ [redacted] វី ភេទប្រុសកើតថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៩៨ កម្រិតវប្បធម៌ថ្នាក់ទី៨ថ្មី ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិត្រពាំងអំពិល ឃុំចាន់សែន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ទីលំនៅសព្វថ្ងៃនៅភូមិត្រពាំងអំពិល ឃុំចាន់សែន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] ថា (រស់) ម្តាយឈ្មោះ [redacted] យ៉ាន (រស់) នៅលីវ, ទោសពីមុន គ្មាន។ ចំពោះឈ្មោះ [redacted] វី នេះ



Scanned with CamScanner

ក្នុងសៀវភៅ ក១ ពុំមានចុះឈ្មោះហៅក្រៅនោះទេ ប៉ុន្តែឈ្មោះនេះខ្លួនហៅគាត់[redacted] វី។ ចំណែកឈ្មោះ រ៉ាវី ប្រហែលជាគ្នាវាពាក់ព័ន្ធនឹងគ្រឿងញៀនហៅវាហើយ។ ឈ្មោះ [redacted] វី ជាមុខសញ្ញាពាក់ព័ន្ធនឹងគ្រឿងញៀនយូរឆ្នាំមកហើយ។ ឈ្មោះនេះបានចាប់ផ្តើមជួញដូរគ្រឿងញៀនតាំងពីថ្ងៃខែឆ្នាំណា ខ្លួនពុំបានដឹងទេ។ នៅក្នុងរឿងនេះ ខ្លួនបានដឹងរឿងតែប៉ុណ្ណឹង។

## តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋាន

តាមរបាយការណ៍សំយោគ និងចម្លើយនៅគ្រប់នីតិវិធី អាចឱ្យតំណាងអយ្យការជឿជាក់បានថា កាលពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ពិតជាមានករណី រក្សាទុក និងជួញដូរគ្រឿងញៀនពិតមែន នៅក្នុងពេលសវនាការ ជនជាប់ចោទបានឆ្លើយបដិសេធនូវរាល់ចម្លើយដែលបានឆ្លើយកន្លងមក តំណាងអយ្យការយល់ឃើញថា ការដោះសារនេះមិនមានភស្តុតាង អាចឱ្យតំណាងអយ្យការអាចជឿជាក់បានយកមកពិចារណាទេ ដូច្នេះ តំណាងអយ្យការនៅតែរក្សាការចោទប្រកាន់ដដែល និងសូមឱ្យក្រុមប្រឹក្សាសម្រេចតាមច្បាប់។

## មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ធ្វើសេចក្តីសន្និដ្ឋាន

ក្នុងករណី នេះព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់កូនក្តីខ្លួនពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ ផ្អែកតាមចម្លើយរបស់កូនក្តីខ្លួននៅគ្រប់ដំណាក់កាលនីតិវិធី ខ្លួនត្រូវបានសមត្ថកិច្ចឃាត់ខ្លួននៅពេលទៅទិញគ្រឿងញៀនចំនួន ២ កញ្ចប់ពីឈ្មោះ ជាតិ ប៉ុន្តែរបាយការណ៍របស់ សមត្ថកិច្ចបានដាក់ថា ៤ កញ្ចប់ទៅវិញ។ ត្រង់ចំណុចនេះ ខ្លួនស្នើសុំឱ្យតុលាការពិនិត្យភស្តុតាងឱ្យបានច្បាស់លាស់ ព្រោះទម្ងន់នៃគ្រឿងញៀនពាក់ព័ន្ធនឹងកម្រិតនៃការផ្តន្ទាទោស។ កូនក្តីខ្លួនក៏បានទទួលសារភាពថា ខ្លួនធ្លាប់ជួយទិញគ្រឿងញៀនឱ្យគេ ដោយគេឱ្យចំណេញបន្តិចបន្តួច ហើយកូនក្តីខ្លួនមិនដែលមានទោសពីមុនមកទេ។ ប្រសិនបើគ្រឿងញៀនពិតជាទម្ងន់ ១០៤.១៤ក្រាម ដូចរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌មែន ហើយផ្អែកតាមលទ្ធផលកោសលវិច័យ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២២ ឃើញថា កម្រិតភាពសុទ្ធមានចំនួនត្រឹមតែ ៧៩.៨១% ហេតុនេះមានន័យថាទម្ងន់គ្រឿងញៀនមេតំហ្វេតាមីន មានបរិមាណធាតុសុទ្ធត្រឹមតែ ៨៣.១១ ក្រាម ប៉ុណ្ណោះ។ យោងតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន បានចែងពាក់ព័ន្ធនឹងការផ្តន្ទាទោសទាក់ទិននឹងបរិមាណធាតុសុទ្ធចាប់ពី ៨០ ក្រាម រហូតដល់ ៦៤០ ក្រាម នោះការផ្តន្ទាទោស ដាក់ពន្ធនាគារគឺអាចចន្លោះពី ១០ ឆ្នាំ ទៅ ២០ ឆ្នាំ និងពិន័យជាប្រាក់ពី ២០ ទៅ ៤០ លានរៀល។ ហេតុនេះ ឃើញថា កម្រិតភាពសុទ្ធនៃមេតំហ្វេតាមីនក្នុងសំណុំរឿងនេះ មានកម្រិតក្បែរអប្បបរមានៃចន្លោះទម្ងន់គ្រឿងញៀនដែលកំណត់ក្នុងមាត្រាដូចលើកឡើងខាងលើ ដូច្នេះសុំឱ្យតុលាការពិចារណាអំពីការផ្តន្ទាទោសដាក់ទៅរកអប្បបរមានៃមូលទោស និងពិចារណាផ្តល់នូវស្ថានសម្រាលទោសដូចលើកឡើងខាងលើ។ បន្ថែមពីលើនេះ ផ្អែកតាមចម្លើយកូនក្តីខ្លួននៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ កូនក្តីខ្លួនបានសហការជាមួយសមត្ថកិច្ច ដោយបានរាយការណ៍អំពីអត្តសញ្ញាណអ្នកលក់គ្រឿងញៀនដែលពាក់ព័ន្ធរួមមានបីនាក់ ដូចជាទី១.ឈ្មោះ ហូវ ភេទប្រុស អាយុ៣០ឆ្នាំ រស់នៅភូមិត្រពាំងអំពិល ឃុំចាន់សែន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ (ជាប់ពន្ធនាគារខេត្តកំពង់ស្ពឺ) ទី២.ឈ្មោះ រ៉ាវី ភេទប្រុស អាយុ២២ឆ្នាំ រស់នៅភូមិត្រពាំងអំពិល ឃុំចាន់សែន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ និងទី៣.ឈ្មោះ ជាតិ ភេទប្រុស អាយុ៤០ឆ្នាំ រស់នៅភូមិត្រពាំង



Scanned with CamScanner

មាន់ ឃុំប្លាយ ស្រុក សំរោងទង ខេត្តកំពង់ស្ពឺ រហូតឈានដល់តុលាការធ្វើការចោទប្រកាន់ និងចាប់ខ្លួនអ្នកពាក់ព័ន្ធបន្ថែម ដូច្នេះ ផ្អែកលើចំណុចទាំងនេះ ខ្លួនស្នើសុំឱ្យតុលាការផ្តល់នូវស្ថានសម្រាលទោសឱ្យកូនក្តីខ្លួន ផ្អែកតាមមាត្រា ៣២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នាំឱ្យអតិបរមា និងអប្បបរមានៃទោសពន្ធនាគារត្រូវបន្ថយពាក់កណ្តាល ហើយអតិបរមា និងអប្បបរមានៃទោសពិន័យជាប្រាក់ក៏ត្រូវបន្ថយពាក់កណ្តាល។ ដូច្នេះទោសពន្ធនាគារដែលអាចត្រូវផ្តន្ទាទោសចំពោះកូនក្តីខ្លួនត្រូវបន្ថយមកត្រឹមចន្លោះពី ៥ ទៅ ១០ឆ្នាំ និងពិន័យជាប្រាក់ពី ១០ ទៅ ២០លានរៀល។ ខ្លួនស្នើសុំឱ្យតុលាការពិចារណាផ្តល់ស្ថានសម្រាលទោសដល់កូនក្តីខ្លួន និងផ្តន្ទាទោសងាកមករកកម្រិតអប្បបរមានៃមូលទោសតាមអានុភាពនៃស្ថានសម្រាលទោសខាងលើ។

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ធ្វើសេចក្តីសន្និដ្ឋាន**

នៅក្នុងរឿងនេះ កូនក្តីរបស់នាងខ្ញុំបានបដិសេធថាមិនបានប្រព្រឹត្តនោះទេ ហើយលោកមេភូមិក៏បានឆ្លើយផងដែរ ហេតុដូច្នេះ សូមទុកសិទ្ធិឱ្យតុលាការសម្រេចតាមច្បាប់។

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]វី និងឈ្មោះ [redacted] ធ្វើសេចក្តីសន្និដ្ឋាន**

ឃើញថា ក្រោយពីបានសួរដេញដោលនាពេលកន្លងមក ពិនិត្យលើអង្គហេតុ កូនក្តីឈ្មោះ [redacted] វី បានឆ្លើយបដិសេធ ហើយចម្លើយរបស់ឈ្មោះ [redacted] ភក្រ្តា ក៏បានឆ្លើយផងដែរថា មិនដែលស្គាល់ឈ្មោះ [redacted] វី នោះទេ ហើយឈ្មោះ [redacted] វី ក៏បានបញ្ជាក់ដែរថា គាត់មិនបានស្គាល់ឈ្មោះ [redacted] ភក្រ្តា ពីមុនមក និងមិនដែលមានទំនាក់ទំនងដែរ។ ចំណែកឈ្មោះ [redacted] ហួរ គឺនៅគ្រប់តំណាក់កាលមិនមានចម្លើយសារភាពរបស់កូនក្តីខ្ញុំទេ ហេតុដូច្នេះ ការដែលតំណាងអយ្យការបានចោទប្រកាន់កូនក្តីនាងខ្ញុំ ឃើញថា មិនមានភស្តុតាងណាច្បាស់លាស់នោះទេ ដែលអាចបញ្ជាក់ថាកូនក្តីនាងខ្ញុំទាំងពីរនាក់នេះពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ផងដែរ មិនមានចម្លើយដែលស៊ីសង្វាក់គ្នា។ ឃើញថាជនជាប់ចោទ [redacted] វី និងឈ្មោះ [redacted] ហួរ មិនបានប្រព្រឹត្តនូវអំពើដែលតំណាងអយ្យការបានចោទប្រកាន់នោះទេ ដោយការចោទប្រកាន់នេះមានត្រឹមតែវិមតិសង្ស័យ គប្បីតុលាការពិនិត្យពិចារណា សម្រេចឱ្យកូនក្តីខ្ញុំទាំងពីរនាក់បានរួចផុតពីបទចោទ តាមមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**សំដីចុងក្រោយរបស់ជនជាប់ចោទ**

ជនជាប់ចោទឈ្មោះ [redacted] ភក្រ្តា បានសំណូមពរថា សូមឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់ខ្លួនផង។

ជនជាប់ចោទឈ្មោះ [redacted] គឹមជាតិ បានសំណូមពរថា សូមឱ្យតុលាការមេត្តាផ្សរកយុត្តិធម៌ឱ្យខ្លួនផង។

ជនជាប់ចោទឈ្មោះ [redacted] វី បានសំណូមពរថា សូមឱ្យតុលាការមេត្តារកយុត្តិធម៌ឱ្យខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ



Scanned with CamScanner

-ក្រោយពីបានពិនិត្យសំណុំរឿង កំណត់ហេតុ ឯកសារភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សាលាដំបូងខេត្តកំពង់ស្ពឺ

## យល់ឃើញថា

១./ កាលពីដើមខែមករា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ មានករណីប្រព្រឹត្តបទល្មើស ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិថ្មីទំលាប់ ឃុំចាន់សែន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ បទល្មើសដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៦ ចំណុច៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន **ពិតប្រាកដមែន**។

២./ របាយការណ៍សំយោគលេខ ១០៨ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២១ របស់ស្នងការដ្ឋាន នគរបាលខេត្តកំពង់ស្ពឺ ការិយាល័យប្រឆាំងគ្រឿងញៀន បានសន្និដ្ឋានថាឈ្មោះ [redacted] ភ័ក្រ្តា ពិតជាមុខសញ្ញាជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនប្រាកដមែន។

៣./ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **គីមជាតិ** បានឆ្លើយបដិសេធថា ខ្លួនមិនដែលបានប្រព្រឹត្តបទល្មើស ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន នោះទេ ហើយខ្លួនក៏មិនស្គាល់ឈ្មោះ [redacted] ភក្រ្តា និងឈ្មោះ [redacted] វី ដែលកំពុងតែមានវត្តមាននៅពេលសវនាការនេះផងដែរ។ តុលាការយល់ឃើញថា ការឆ្លើយបដិសេធរបស់ជនជាប់ចោទឈ្មោះ [redacted] គីមជាតិ មានហេតុផលគ្រប់គ្រាន់ ដោយផ្អែកលើចម្លើយរបស់សាក្សីជាអាជ្ញាធរនៅក្នុងមូលដ្ឋាន៖

-លោក [redacted] ជាមេភូមិ ភូមិថ្មី បានឆ្លើយថា "...នៅក្នុងសៀវភៅ ក១ មិនមានឈ្មោះ [redacted] គីមជាតិ នោះទេ ដោយគាត់ពុំបានផ្លាស់ទីលំនៅពីភូមិត្រពាំងតាមាន់ មករស់នៅភូមិថ្មី ជង្រុកឡើយ ប៉ុន្តែគាត់បានមករស់នៅភូមិថ្មីជង្រុក ស្រុកថ្ពង ខេត្តកំពង់ស្ពឺ តាំងពីឆ្នាំ២០១០ មកម្ល៉េះ បន្ទាប់ពីគាត់រៀបការប្រពន្ធរួចហើយ នៅក្នុងភូមិគាត់មានមុខរបរ ជាកសិករ និងដុតឡឥដ្ឋ។ ឈ្មោះនេះ ពុំមែនជាមុខសញ្ញាពាក់ព័ន្ធនឹងគ្រឿងញៀននោះទេ..." ។

-លោក [redacted] ឈុន ជាមន្ត្រីនគរបាលយុត្តិធម៌ បានឆ្លើយថា "...ឈ្មោះ [redacted] គីមជាតិ តាមការទទួលដំណឹងពីលោកអនុភូមិឈ្មោះ [redacted] សារិទ្ធ បានឱ្យដឹងថា ឈ្មោះ [redacted] គីមជាតិ បានទៅរស់នៅភូមិថ្មី ឃុំយាអង្គ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ តាំងពីគាត់រៀបការជាមួយប្រពន្ធគាត់ ប៉ុន្តែមិនបានធ្វើឯកសារផ្លាស់ប្តូរទីលំនៅឡើយ។ ឈ្មោះនេះអំឡុងពេលដែលរស់នៅភូមិត្រពាំងតាមាន់ ឃុំក្លាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ពុំមានប្រព្រឹត្តបទល្មើសអ្វីឡើយ..." ។

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ភក្រ្តា បានឆ្លើយថា "...ចំពោះឈ្មោះ ជាតិ ([redacted] គីមជាតិ) ដែលមានវត្តមាននៅពេលនេះ ខ្លួនមិនដែលស្គាល់នោះទេ..." ។

ផ្អែកតាមភាពស៊ីសង្វាក់នៃចម្លើយរបស់ជនជាប់ចោទ និងចម្លើយរបស់សាក្សី តុលាការអាចជឿជាក់បានថា ជនជាប់ចោទរូបនេះពិតជាមិនបានប្រព្រឹត្តបទល្មើស ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន **នោះទេ**។

៤./ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ភ័ក្រ្តា នាពេលសវនាការ បានឆ្លើយថា នៅថ្ងៃកើតហេតុខ្លួនពិតជាបានទិញគ្រឿងញៀន ដើម្បីយកមកលក់បន្តពិតមែន ដោយក្រោយពេលទិញបានហើយយកមករំលែក

ជាកញ្ចប់តូចៗលក់បន្តក្នុងមួយកញ្ចប់តម្លៃ ២០០០០ ម៉ឺនរៀល។ កន្លងមកខ្លួនធ្លាប់ប្រើប្រាស់គ្រឿងញៀន និងធ្លាប់បានទិញគ្រឿងញៀនពីឈ្មោះ [redacted] វី និងឈ្មោះ [redacted] ផងដែរ។ ឃើញថា អំពើដែលជនជាប់ចោទរូបនេះបានប្រព្រឹត្តជាបទល្មើស **រក្សាទុក និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៦ ចំណុច៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន គប្បីតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទរូបនេះតាមច្បាប់។

៥./ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វី នៅពេលសវនាការ បានឆ្លើយថា ខ្លួនចេះប្រើប្រាស់គ្រឿងញៀន ប៉ុន្តែមិនដែលលក់គ្រឿងញៀននោះទេ។ គ្រឿងញៀនដែលប្រើប្រាស់គឺទិញពីឈ្មោះ ហេល។ សមត្ថកិច្ចចាប់រូបខ្លួន គឺចាប់នៅក្នុងករណីផ្សេងមិនមែននៅក្នុងសំណុំរឿងនេះនោះទេ និងបានអះអាងថាសមត្ថកិច្ចចាប់រូបខ្លួនដោយសមត្ថកិច្ចបានអះអាងថាខ្លួនមានឈ្មោះ [redacted] វី ជាក់ស្តែងខ្លួនឈ្មោះ [redacted] វី មិនមែនឈ្មោះ [redacted] វី ដូចដែលសមត្ថកិច្ចបានអះអាងនោះទេ។ ឃើញថា ការឆ្លើយរបស់ជនជាប់ចោទរូបនេះ គ្រាន់តែជាការឆ្លើយដោះសារដើម្បីអាចបានរួចផុតពីការចោទប្រកាន់តែប៉ុណ្ណោះ ជនជាប់ចោទរូបនេះមិនមានភស្តុតាង ឬសាក្សីបង្ហាញមកតុលាការនោះទេ ប៉ុន្តែផ្ទុយទៅវិញ មានភស្តុតាង និងសាក្សីគ្រប់គ្រាន់ ដែលអាចឱ្យតុលាការជឿជាក់បានថាជនជាប់ចោទឈ្មោះ [redacted] វី ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ពិតមែន ក្នុងនោះចម្លើយរបស់លោក [redacted] ប៊ុនឆេង ជាមន្ត្រីនគរបាលយុត្តិធម៌ និងលោក [redacted] រ៉ាន់ ជាមេភូមិត្រពាំងអំពិល បានឆ្លើយដូចគ្នាថា ឈ្មោះ [redacted] វី គឺបានស្រង់ចេញពីសៀវភៅ ក១ ដែលបានទីកន្លែងកំណើតនិងទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងអំពិល ឃុំចាន់សែន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ដែលនៅក្នុងមូលដ្ឋាននេះមិនមានឈ្មោះ[redacted]វី នោះទេ គឺមានតែឈ្មោះ [redacted] វី ហើយឈ្មោះ [redacted] វី នេះគឺជាមុខសញ្ញាជួញដូរគ្រឿងញៀននៅក្នុងមូលដ្ឋានយ៉ាងសកម្ម។ ហើយឈ្មោះ [redacted] វី ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានហៅ [redacted] វ៉ាវី។ ឃើញថា តាមភាពស៊ីសង្វាក់នៃចម្លើយរបស់សាក្សី ភស្តុតាង តុលាការអាចជឿជាក់បានថាជនជាប់ចោទឈ្មោះ [redacted] វី ពិតជាបានប្រព្រឹត្តបទល្មើស **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៦ ចំណុច៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន គប្បីតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទរូបនេះតាមច្បាប់។

៦./ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ភក្ត្រា បាននាពេលសវនាការឆ្លើយថា គ្រឿងញៀនដែលខ្លួនយកមកប្រើប្រាស់គឺបានទិញពីឈ្មោះ ហួរ ([redacted] ហួរ)។ ឃើញថា អំពើដែលជនជាប់ចោទឈ្មោះ [redacted] ហួរ បានប្រព្រឹត្តជាបទល្មើស **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៦ ចំណុច៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន គប្បីតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទរូបនេះតាមច្បាប់។

៨./ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ភក្ត្រា បានធ្វើសេចក្តីសន្និដ្ឋានថា "...សូមឱ្យតុលាការមេត្តាផ្តល់ការសម្រាលទោសឯកទៅរកអប្បបរមានៃទោសដែលត្រូវទទួល ដោយផ្អែកលើការឆ្លើយរាយការណ៍របស់ជនជាប់ចោទ..." គប្បីតុលាការលើកមកពិនិត្យ ពិចារណា និងសម្រេចតាមច្បាប់។



Scanned with CamScanner

៩./ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ហួរ និងឈ្មោះ [redacted] វី បានធ្វើសេចក្តីសន្និដ្ឋានថា "...សូមឱ្យតុលាការឱ្យកូនក្តីរបស់ខ្លួនបានរួចផុតពីការបទចោទប្រកាន់ មាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយហេតុថា ការចោទប្រកាន់របស់តំណាងអយ្យការមិនមានភស្តុតាងគ្រប់គ្រាន់ ហើយមានវិមតិសង្ស័យចំពោះជនជាប់ចោទទាំងពីរនាក់ទៀតផង..." គប្បីតុលាការលើកមកពិនិត្យ ពិចារណា និងសម្រេចតាមច្បាប់។

១០./ ឃើញថា តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ សូមតម្កល់ការចោទប្រកាន់នៅរងដែលតុលាការ គប្បីលើកមកពិចារណា។

១១./ មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ភក្ត្រា ភេទប្រុស ពីបទ **រក្សាទុក និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិថ្មីទំលាប់ ឃុំចាន់សែន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៦ ចំណុច៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ ជនជាប់ចោទឈ្មោះ [redacted] ហួរ ភេទប្រុស និងឈ្មោះ [redacted] វី ភេទប្រុស ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិថ្មីទំលាប់ ឃុំចាន់សែន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ កាលពីដើមខែមករា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៦ ចំណុច៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១២./ មានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ ដែលអាចធ្វើការចោទប្រកាន់ជនជាប់ចោទឈ្មោះ [redacted] ភក្ត្រា ភេទប្រុស ពីបទ **រក្សាទុក និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិថ្មីទំលាប់ ឃុំចាន់សែន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៦ ចំណុច៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ ជនជាប់ចោទឈ្មោះ [redacted] ហួរ ភេទប្រុស និងឈ្មោះ [redacted] វី ភេទប្រុស ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិថ្មីទំលាប់ ឃុំចាន់សែន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ កាលពីដើមខែមករា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៦ ចំណុច៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១៣./ មិនមានធាតុផ្សំ ភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] គីមជាតិ ភេទប្រុស ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិថ្មីទំលាប់ ឃុំចាន់សែន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ កាលពីដើមខែមករា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ បតល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៦ ចំណុច៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១៤./ ឃើញថាជនជាប់ចោទឈ្មោះ [redacted] ហួរ ភេទប្រុស អវត្តមាននាពេលសវនាការ។ ជនជាប់ចោទត្រូវបានតុលាការការផ្តន្ទាទោសដាក់ពន្ធនាគារលើសពីមួយឆ្នាំដោយគ្មានការព្យួរទោស។ ដោយហេតុថាមានការព្រួយបារម្ភថាជនជាប់ចោទ បានរត់គេចខ្លួនដែលអាចបន្តប្រព្រឹត្តបទល្មើសសារជាថ្មី ធ្វើឱ្យប៉ះពាល់ដល់សង្គម ហេតុនេះតុលាការគប្បីចេញដីកាបង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទរូបនេះយកមកឃុំខ្លួនក្នុងពន្ធនាគារតាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។



Scanned with CamScanner

១៥./ ឃើញថាលទ្ធផលកោសលវិច័យនៃសំណាកគ្រឿងញៀនបង្ហាញថា លទ្ធផលធាតុសុទ្ធនៃគ្រឿងញៀនរបស់ឈ្មោះ [redacted] ភក្ត្រា មានចំនួន ៧៩.៨១% នៃចំនួនគ្រឿងញៀនសរុប ចំនួន ១០៣.៧៦ ក្រាម ជាលទ្ធផលសារធាតុញៀនសុទ្ធគឺមានចំនួន ៨៧.៦៨ ក្រាម។ មាត្រា ៤០ កថាខណ្ឌ៦ ចំណុច៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចំពោះបរិមាណសុទ្ធចាប់ពី ៨០ (ប៉ែតសិប) ក្រាម រហូតដល់ក្រោម ២៤០ (ពីររយសែសិប) ក្រាម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ចំនួនពី ១០ (ដប់) ទៅ ២០ (ម្ភៃ) ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី ២០,០០០, ០០០ (ម្ភៃលាន) ទៅ ៤០,០០០,០០០ (សែសិបលាន) រៀល ដូច្នេះ គប្បីតុលាការពិចារណានិងសម្រេចតាមច្បាប់។

១៦./ វត្ថុតាងដែលបានទទួលបាននៅក្នុងសំណុំរឿងមាន ទូរស័ព្ទដៃ៤គ្រឿង, ដាវ៣ដើម, កាំភ្លើងខ្យល់១ដើម, ជញ្ជីងថ្លឹងគ្រឿងញៀន២គ្រឿង, ឧបករណ៍សម្រាប់ប្រើប្រាស់គ្រឿងញៀនមួយចំនួន និងគ្រឿងញៀនដែលនៅសល់ក្រោយពេលដកសំណាកចំនួន ៨៤,៧៦ ក្រាម គប្បីតុលាការលើកមកពិនិត្យ និងពិចារណា។

## ហេតុដូច្នេះសម្រេច

**១**./ ឱ្យជនជាប់ចោទឈ្មោះ [redacted] **គីមជាតិ** ហៅ ជាតិ ភេទប្រុស កើតឆ្នាំ១៩៨៦ ជនជាតិខ្មែរ **បានរួចខ្លួន** <u>ពីបទ</u> **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិថ្មីទំលាប់ ឃុំចាន់សែន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ កាលពីដើមខែមករា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៦ ចំណុច៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**២./ ផ្តន្ទាទោសលើជនជាប់ចោទ**

២.១./ ឈ្មោះ [redacted] **ភក្ត្រា** ហៅ ញ៉ាញ់ ភេទប្រុស កើតឆ្នាំ១៩៨៨ ដាក់ពន្ធនាគារកំណត់ចំនួន **១២ (ដប់ពីរ) ឆ្នាំ** និងពិន័យជាប្រាក់ចំនួន **២០,០០០,០០០** (ម្ភៃលាន) រៀល <u>ពីបទ</u> **រក្សាទុក និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិថ្មីទំលាប់ ឃុំចាន់សែន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ ២០២១ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៦ ចំណុច៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២.២./ ឈ្មោះ [redacted] **វី** ហៅវ៉ាវី ភេទប្រុស កើតឆ្នាំ១៩៩៨ ជនជាតិខ្មែរ

២.៣./ ឈ្មោះ [redacted] **ហួរ** ហៅហួរ ភេទប្រុស កើតឆ្នាំ១៩៨៧ ជនជាតិខ្មែរ

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ចំនួន **១០ (ដប់) ឆ្នាំ** និងពិន័យជាប្រាក់ក្នុងម្នាក់ៗចំនួន **២០,០០០, ០០០** (ម្ភៃលាន) រៀល <u>ពីបទ</u> **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិថ្មីទំលាប់ ឃុំចាន់សែន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ កាលពីដើមខែមករា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៦ ចំណុច៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣./ ចេញដីកាបង្គាប់ឱ្យចាប់ខ្លួន និងឃុំខ្លួនលើជនជាប់ចោទឈ្មោះ [redacted] **ហួរ** ភេទប្រុស កើតឆ្នាំ ១៩៨៧ ជនជាតិខ្មែរ ដាក់ពន្ធនាគារខេត្តកំពង់ស្ពឺ តាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។



Scanned with CamScanner

៤./ វត្ថុតាង រួមមាន ទូរស័ព្ទចំនួន៤គ្រឿង, ដាវ៣ដើម, ឧបករណ៍ប្រើប្រាស់គ្រឿងញៀនមួយចំនួន, ជញ្ជីងថ្លឹងគ្រឿងញៀន២គ្រឿង, គ្រឿងញៀននៅសល់ក្រោយពេលដកសំណាកចំនួន ៨៤,៧៦ក្រាម **សម្រេចរឹបអូស**។

៥./ សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៤ និងប្រកាសជាសាធារណៈនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៤ ចំពោះមុខជនជាប់ចោទ [redacted] រី, ឈ្មោះ [redacted] គឹមជាតិ និងឈ្មោះ [redacted] ភក្ត្រា កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ហួរ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| **ក្រឡាបញ្ជី** | **សមាជិកក្រុមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

---

| បានឃើញ | បានចម្លងត្រឹមត្រូវតាមច្បាប់ដើម |
|---|---|
| **ប្រធានក្រុមប្រឹក្សា** | ថ្ងៃព្រហស្បតិ៍ ១៣កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ |
| | កំពង់ស្ពឺ, ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៤ |
| | **ក្រឡាបញ្ជី** |
| [redacted] | [redacted] |



Scanned with CamScanner